# សេចក្តីប្រកាសព័ត៌មាន

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា("ម.ស.ម.ក")ប្រកាសផ្សព្វផ្សាយមេរៀនស្តីពី សេរីភាពខាងការបញ្ចេញមតិ

**រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១**

គម្រោង "លើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា" នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមប្រកាសផ្សព្វផ្សាយមេរៀនតាមប្រព័ន្ធអនឡាញទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិចំនួនបី ដើម្បីពង្រឹងចំណេះដឹងដល់សាធារណជនអំពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ មេរៀននីមួយៗរួមមាន វីឌេអូ ប័ណ្ណព័ត៌មាន និងសំណួរដែលរៀបរាប់លម្អិតអំពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។

កម្មវិធីប្រកាសផ្សព្វផ្សាយមេរៀននេះនឹងត្រូវធ្វើឡើងនៅលើប្រព័ន្ធអនឡាញ នា**ថ្ងៃអង្គារ ទី១៣ ខែកក្កដា ឆ្នាំ២០២១ ចាប់ពីម៉ោង ១:៣០ រសៀល ដល់ ៥:០០ ល្ងាច។**

**កម្មវិធីនេះមានគោលបំណង៖**

- លើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
- បង្ហាញនូវប័ណ្ណព័ត៌មាន និងវីឌេអូទាក់ទងនឹងខ្លឹមសារមេរៀននីមួយៗ និង
- ចូលរួមធ្វើតេស្តដោយផ្ទាល់ទាក់ទងនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ តាមរយៈប្រព័ន្ធអនឡាញ។

កម្មវិធីនេះនឹងចាប់ផ្តើមដោយមានមតិស្វាគមន៍របស់ **លោកស្រី ចក់ សុភាព** នាយិកាប្រតិបត្តិនៃ ម.ស.ម.ក ហើយបន្ទាប់មកនឹងមានបទបង្ហាញអំពីមេរៀនទាំងបី នៅលើគេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជានៃ ម.ស.ម.ក (https://sithi.org/km/foe)។ បន្ថែមពីនេះ ក្រុមការងារគម្រោងនឹងចាក់បញ្ចាំងវីឌេអូទាក់ទងនឹងខ្លឹមសារមេរៀននីមួយៗ។ បន្ទាប់ពីការបង្ហាញអំពីមេរៀនទាំងនេះ អ្នកចូលរួមអាចចូលរួមឆ្លើយសំណួរតាមប្រព័ន្ធអនឡាញស្តីពី សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដើម្បីមានឱកាសទទួលបានរង្វាន់ជបទឹកដែលមានសរសេរសោរថា "*យើងគាំទ្រសេរីភាពខាងការបញ្ចេញមតិ*"។ កម្មវិធីនេះនឹងបញ្ចប់ដោយការថ្លែងសុន្ទរកថាដោយលោកស្រី ចក់ សុភាព ផងដែរ។

**កម្មវិធី៖** ការប្រកាសផ្សព្វផ្សាយមេរៀនតាមប្រព័ន្ធអនឡាញស្តីពីសេរីភាពខាងការបញ្ចេញមតិ
**កាលបរិច្ឆេទ៖** ថ្ងៃអង្គារ ទី១៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១:៣០ រសៀល ដល់ ៥:០០ ល្ងាច
**ទីកន្លែង៖** តាមប្រព័ន្ធអនឡាញ និងផ្សាយផ្ទាល់តាមរយៈហ្វេសប៊ុករបស់ ម.ស.ម.ក៖ cchrcambodia

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក **ហួន ផន** អ្នកសម្របសម្រួលគម្រោង "លើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា" នៃ ម.ស.ម.ក តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ លេខទូរស័ព្ទ ០៧០ ៧៥៧ ៨៨៤ ។

**– ចប់ –**

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។
ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (OMCT SOS-Torture Network) និងជាសមាជិក OECD Watch។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org បានទទួលពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងបានទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសប៊ែន នៃប្រទេសអូស្ត្រាលី។